Eat Well, Live Well.

AJINOMOTO®

# AGP

## Ajinomoto Group Policies

Khmer

ភាសាខ្មែរ

# មាតិកា


សារពីលោកប្រធាននិងអគ្គនាយកប្រតិបត្តិ ........ 1

អ្វីទៅ AGP (Ajinomoto Group Policies)? ........ 2

វិសាលភាពនៃការអនុវត្ត ........ 2

ការទទួលខុសត្រូវរបស់ក្រុមហ៊ុន ........ 2

គោលការណ៍មូលដ្ឋាន ........ 3

មូលដ្ឋានគ្រឹះនៃអភិបាលកិច្ច និងទំនុកចិត្ត

1. ការរៀបចំនិងការអនុវត្តអភិបាលកិច្ចល្អ ........ 3

បេសកកម្មសង្គមរបស់ក្រុមហ៊ុន និងការផ្តល់តម្លៃ

2. សកម្មភាពពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ........ 4
3. គំនិតផ្តួចផ្តើមស្តីពីសុខភាព និងអាហារូបត្ថម្ភ ........ 5
4. វិភាគទានចំពោះបរិស្ថាននិងនិរន្តរភាពនៃផែនដី ........ 6

ការទទួលខុសត្រូវចំពោះអ្នកពាក់ព័ន្ធ

5. អតិថិជន : ការផ្គត់ផ្គង់ផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់និងសុវត្ថិភាពល្អ ........ 7
6. ដៃគូអាជីវកម្ម : ប្រតិបត្តិការប្រកបដោយតម្លាភាពនិងយុត្តិធម៌ ........ 8
7. វិនិយោគិន និងម្ចាស់ភាគហ៊ុន : ទំនុកចិត្ត និងការទទួលខុសត្រូវ ........ 10
8. សហគមន៍ : ធ្វើការងារជាមួយសហគមន៍ ........ 11
9. អ្នកនយោបាយ និងរដ្ឋាភិបាល : ទំនាក់ទំនងប្រកបដោយតម្លាភាព ........ 12
10. បុគ្គលិក : ការបណ្តុះបណ្តាលបុគ្គលិក និងការធានាសុវត្ថិភាព ........ 13

និរន្តរភាពផ្ទៃក្នុង និងស្តង់ដារនៃការប្រព្រឹត្តផ្ទាល់ខ្លួន

11. ការការពារ និងគ្រប់គ្រងទ្រព្យសម្បត្តិ និងព័ត៌មានរបស់ក្រុមហ៊ុន ........ 14
12. ការបំបាត់ភាពចម្លែករវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍អាជីវកម្ម ........ 15


# សារពីលោកប្រធាននិងអគ្គនាយកប្រតិបត្តិ



គោលបំណងរបស់ Ajinomoto Group យើងខ្ញុំគឺ ការធ្វើ "វិភាគទានចំពោះសុខុមាលភាពមនុស្សជាតិ សង្គម និងផែនដីរបស់យើងទាំងអស់គ្នា តាមរយៈ AminoScience"។ ហេតុនេះហើយបានជាយើងបានផ្តួចផ្តើមស្វែងរក ASV (The Ajinomoto Group Creating Shared Value) - នេះគឺជាវិធីសាស្ត្រដ៏ពិសេសមួយដើម្បីដោះស្រាយបញ្ហាសង្គម តាមរយៈអាជីវកម្មរបស់យើង និងអភិវឌ្ឍតម្លៃសេដ្ឋកិច្ចតាមរយៈការបង្កើតតម្លៃជារួមជាមួយនឹងសង្គម ព្រមទាំងសហគមន៍មូលដ្ឋាន។

ការផ្តួចផ្តើមស្វែងរក ASV នេះអាចធ្វើទៅបានទាល់តែមានសហប្រតិបត្តិការពីសំណាក់ម្ចាស់ហ៊ុននិងវិនិយោគិននានា ហើយសហប្រតិបត្តិការនេះអាចកើតមានឡើងតែតាមរយៈការខំប្រឹងប្រែងយ៉ាងខ្លាំងរបស់ Group យើង ដើម្បីទទួលបាននូវទំនុកចិត្តពីសង្គម។ ការលើកកម្ពស់ភាពសុចរិត-ដោយបុគ្គលិកម្នាក់ៗទទួលខុសត្រូវលើវិធីសាស្ត្រ និងឥរិយាបថរបស់ពួកគេ គិតដោយឯករាជ្យ ធ្វើការវិនិច្ឆ័យត្រឹមត្រូវ និងធ្វើសកម្មភាពដោយស្មោះត្រង់-លើកទឹកចិត្តដល់ការគ្រប់គ្រង ASV ហើយមូលដ្ឋានគ្រឹះសម្រាប់ភាពសុចរិតនេះស្ថិតនៅលើគោលការណ៍ក្រុមហ៊ុន Ajinomoto (AGP)។ បុគ្គលិកក្រុមហ៊ុន Ajinomoto ម្នាក់ៗ ដែលត្រូវបានដឹកនាំដោយគោលការណ៍ដែលមានចែងក្នុង AGP និងប្រើប្រាស់ការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់ពួកគេដើម្បីធ្វើសកម្មភាពដោយភាពសុចរិត - អ្វីដែលយើងហៅថា " Think Well, Do Well " - ពង្រឹងវប្បធម៌អង្គភាពយើង និងបង្កើតតម្លៃរួមរបស់ Ajinomoto Group។

AGP បង្ហាញពីជំនឿ និងឥរិយាបថដែលក្រុមហ៊ុននានាក្នុង Group និងយើងម្នាក់ៗដែលធ្វើការនៅទីនោះគួរប្រកាន់ខ្ជាប់ និងអនុវត្តក្នុងសកម្មភាពទាំងអស់របស់យើង ព្រមទាំងផ្តល់ការប្តេជ្ញាចិត្តជាលាយលក្ខណ៍អក្សរដល់ភាគីពាក់ព័ន្ធទាំងអស់របស់យើងថា យើងនឹងប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងនេះ។ គោលដៅរបស់យើងខ្ញុំគឺ ការធ្វើវិភាគទានចំពោះសុខុមាលភាពមនុស្សជាតិ សង្គម និងផែនដីរបស់យើងទាំងអស់គ្នា តាមរបៀបដែលអាចទទួលបាននូវជំនឿទុកចិត្តគាំទ្រ AGP ក្នុងសកម្មភាពនានារបស់យើងខ្ញុំ។

Shigeo Nakamura

លោក Shigeo Nakamura
ប្រធាន
តំណាងនាយកប្រតិបត្តិ
ប្រធាននិងអគ្គនាយកប្រតិបត្តិនៃ Ajinomoto Co., Inc.

## អ្វីទៅ AGP (Ajinomoto Group Policies)?

AGP បានកំណត់នូវជំនឿ និងអាកប្បកិរិយាដែលក្រុមហ៊ុនក្នុង Ajinomoto Group ទាំងអស់ និងពួកយើងម្នាក់ៗដែលបានប្ដេជ្ញាចិត្ត។ AGP គឺជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរដល់ភាគីពាក់ព័ន្ធទាំងអស់ សន្យាថា នឹងធ្វើការដោយស្មោះស្ម័គ ដើម្បីរក្សាជំនឿ និងអាកប្បកិរិយាទាំងនេះ។

AGP មានគោលការណ៍មូលដ្ឋានចំនួន 12 និងស៊េរីនៃគោលការណ៍របស់ Group ដែលពាក់ព័ន្ធ។

AGP ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Ajinomoto Co., Inc. នៅថ្ងៃទី 30 ខែឧសភា ឆ្នាំ 2018 ដោយផ្អែកទៅលើក្រមប្រតិបត្តិរបស់ Ajinomoto Group ដែលបានបង្កើតឡើងនៅខែមេសា ឆ្នាំ 2000 ហើយកែលម្អជាបន្តបន្ទាប់នៅឆ្នាំ 2009  ឆ្នាំ 2014  និងឆ្នាំ 2017។ AGPនឹងត្រូវបានកែសម្រួលតាមការចាំបាច់។

## វិសាលភាពនៃការអនុវត្ត

AGP ត្រូវអនុវត្តចំពោះក្រុមហ៊ុន និងអ្នកដឹកនាំ និង បុគ្គលិកទាំងអស់នៃ Ajinomoto Group។

Ajinomoto ក៏លើកទឹកចិត្តអ្នកផ្គត់ផ្គង់ និងដៃគូអាជីវកម្មផ្សេងទៀតនៅក្នុងខ្សែសង្វាក់តម្លៃរបស់ខ្លួនឱ្យរក្សាស្មារតីនៃ AGP នៅក្នុងសកម្មភាពរបស់ពួកគេ។

## ការទទួលខុសត្រូវរបស់ក្រុមហ៊ុន

- Ajinomoto Group ក៏លើកទឹកចិត្តអ្នកផ្គត់ផ្គង់ និងដៃគូអាជីវកម្មផ្សេងទៀតនៅក្នុងខ្សែសង្វាក់តម្លៃរបស់ខ្លួន ឱ្យរក្សាស្មារតីរបស់ AGP នៅក្នុងសកម្មភាពរបស់ពួកគេ។
- ក្រុមហ៊ុននីមួយៗនៃ Ajinomoto Group មិនចេញបញ្ជាចំពោះអ្នកដឹកនាំ ឬបុគ្គលិករបស់ខ្លួនឱ្យប្រព្រឹត្តផ្ទុយនឹង AGP នេះឡើយ។ ម្យ៉ាងទៀត ក្រុមហ៊ុននីមួយៗនៃ Ajinomoto Group មិនដាក់ទោសធ្វើឱ្យបាត់បង់ផលប្រយោជន៍អ្នកដឹកនាំ ឬបុគ្គលិក ដោយមូលហេតុថា អ្នកនោះបានគោរព AGP នេះឡើយ។
- ថ្នាក់ដឹកនាំនៃក្រុមហ៊ុននីមួយនៃ Ajinomoto Group ត្រូវយល់ដឹងអំពីតួនាទីរបស់ខ្លួនក្នុងការគោរពតាម AGP នេះ និងបង្កើតជាឧទាហរណ៍គំរូនៃការគោរពច្បាប់ ហើយត្រូវនាំមុខក្នុងការអនុវត្តតាម ព្រមទាំងធានានូវការគោរពច្បាប់ក្នុងក្រុមហ៊ុន ហើយបង្កើតនូវប្រព័ន្ធខាងក្នុងដែលមានប្រសិទ្ធិភាពបញ្ចូលនូវមតិរបស់អ្នកខាងក្នុងនិងខាងក្រៅក្រុមហ៊ុន។
- នៅពេលមានការរំលោភធ្ងន់ធ្ងរទៅលើ AGP ដូចជា ច្បាប់និងបទដ្ឋានគតិយុត្ត ជាដើម ថ្នាក់ដឹកនាំនៃក្រុមហ៊ុននីមួយៗ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីគោលជំហររបស់ខ្លួនជូនម្ចាស់ហ៊ុននិងវិនិយោគិន ហើយខំប្រឹងស្រាវជ្រាវនូវមូលហេតុ និងចាត់វិធានការចាំបាច់ដើម្បីបង្ការកុំឱ្យបញ្ហាដូចគ្នានោះកើតមានឡើងជាថ្មីម្តងទៀត។

# គោលការណ៍មូលដ្ឋាន

## មូលដ្ឋានគ្រឹះនៃអភិបាលកិច្ច និងទំនុកចិត្ត

### 1. ការរៀបចំនិងការអនុវត្តអភិបាលកិច្ចល្អ

1.1 យើងអនុវត្តតាមច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងធ្វើសកម្មភាពស្របតាម AGP ដែលជាគំរូសីលធម៌របស់យើងផ្ទាល់។

1.2 យើងខ្ញុំបង្កើតប្រព័ន្ធអធិការកិច្ចដែលមានគណកម្មការតំណាង គណនេយ្យភាព ព្រមទាំងគ្រប់គ្រង  ក្រុមហ៊ុនក្នុងក្រុម តាមវិធីដែលមានសមធម៌ តម្លាភាព និងមានប្រសិទ្ធភាព ដើម្បីបង្កើនតម្លៃរបស់ក្រុមហ៊ុនជានិរន្តរ។

1.3 យើងខ្ញុំអនុវត្តយុទ្ធសាស្រ្តគ្រប់គ្រងហានិភ័យ និងរៀបចំគ្រប់គ្រងហានិភ័យ ដើម្បីត្រៀមខ្លួនចំពោះបញ្ហានយោបាយ សេដ្ឋកិច្ច និងសង្គម ដូចជា ភេរវកម្ម ការវាយប្រហារតាមអ៊ីនធឺណិត និងគ្រោះធម្មជាតិ។

1.4 ក្នុងករណីដែលយើងខ្ញុំជាប់ពាក់ព័ន្ធនឹងអំពើអយុត្តិធម៌ ឬអំពើផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្ត ឬផ្ទុយនឹង AGP យើងខ្ញុំនឹងបង្ហាញជាសាធារណៈ។ យើងខ្ញុំនឹងពិគ្រោះជាមួយនឹងថ្នាក់ដឹកនាំសមស្រប ហើយប្រើប្រាស់ប្រព័ន្ធផ្តល់របាយការណ៍អនាមិករបស់យើងខ្ញុំ ដើម្បីស្វែងយល់អំពីអំពើ ឬបញ្ហានោះឱ្យបានច្បាស់លាស់។

1.5 យើងខ្ញុំដាច់ខាតមិនចូលពាក់ព័ន្ធនឹងកងកម្លាំងប្រឆាំងសង្គមដែលធ្វើឱ្យខូចសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈឡើយ។ លើសពីនេះ យើងខ្ញុំតាំងចិត្តប្រឆាំងនឹងកងកម្លាំងប្រឆាំងសង្គម ហើយមិនឆ្លើយតបចំពោះការទាមទារដែលមិនត្រឹមត្រូវជាដាច់ខាត។

**គោលការណ៍ជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីអភិបាលកិច្ច
- គោលការណ៍ជារួមក្នុងក្រុមស្តីពីការគ្រប់គ្រងហានិភ័យ
- គោលការណ៍ជារួមក្នុងក្រុមស្តីពីគណនេយ្យ
- គោលការណ៍ជារួមក្នុងក្រុមស្តីពីការបង្ការការក្លែងបន្លំ និងការកិបកេងប្រាក់
- គោលការណ៍ជារួមក្នុងក្រុមស្តីពីការផ្តល់ព័ត៌មានមិនពិត

# បេសកកម្មសង្គមរបស់ក្រុមហ៊ុន និងការផ្តល់តម្លៃ

## 2. សកម្មភាពពាក់ព័ន្ធនឹងសិទ្ធិមនុស្ស

2.1 យើងធ្វើសកម្មភាពអាជីវកម្មដោយផ្អែកលើសិទ្ធិមនុស្សដែលអន្តរជាតិទទួលស្គាល់ ហើយគោរពក្រមប្រតិបត្តិអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

2.2 យើងខ្ញុំខំប្រឹងប្រែងសហប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនយ៉ាងទូលំទូលាយ ដើម្បីកុំឱ្យចូលរួមក្នុងការបំពានសិទ្ធិមនុស្ស។ យើងធ្វើការរួមគ្នាជាមួយអ្នកពាក់ព័ន្ធជាច្រើន ហើយធ្វើការពិនិត្យមើលសិទ្ធិមនុស្សយ៉ាងម៉ត់ចត់ ដើម្បីធានាថា យើងមិនចូលរួម ឬរួមចំណែកដល់ការរំលោភសិទ្ធិមនុស្សឡើយ។ លើសពីនេះ ប្រសិនបើវាច្បាស់ណាស់ថាយើងបានបង្ក ឬរួមចំណែកដល់ផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិមនុស្ស យើងនឹងខិតខំប្រឹងប្រែងអនុវត្តវិធានការកែតម្រូវ និងដោះស្រាយឱ្យបានឆាប់រហ័ស។

2.3 យើងគោរពច្បាប់និងបទដ្ឋានគតិយុត្ត និងវប្បធម៌នៃប្រទេស ឬតំបន់ដែលយើងប្រកបអាជីវកម្ម។ យើងមិនរើសអើងជាតិសាសន៍ និងយាយីអ្នកណាម្នាក់ ពាក់ព័ន្ធនឹងសញ្ជាតិ សាសនា ជំនឿ កំណើត ភេទ អាយុ ពិការភាព ទំនោរផ្លូវភេទ អត្តសញ្ញាណភេទ ឬកត្តាណាមួយផ្សេងឡើយ។

2.4 យើងខ្ញុំប្តេជ្ញាលុបបំបាត់ពលកម្មលើកុមារ និងពលកម្មដោយបង្ខំ ព្រមទាំងធានាបរិយាកាសការងារប្រកបដោយសុវត្ថិភាព មានសុខភាពល្អ និងមានផាសុកភាព។ យើងគោរពសិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការ រួមទាំងសេរីភាពក្នុងការបង្កើតសហជីព សេរីភាពក្នុងការរៀបចំ និងសិទ្ធិចរចាជាសមូហភាព។

**គោលការណ៍ជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីសិទ្ធិមនុស្ស

## 3. គំនិតផ្តួចផ្តើមស្តីពីសុខភាព និងអាហារូបត្ថម្ភ

3.1 យើងខ្ញុំចូលរួមចំណែកដល់ការទទួលទានអាហារ និងរបៀបរស់នៅដែលមានសុខភាពល្អជាងមុន ដោយយល់ដឹងស៊ីជម្រៅអំពីតម្រូវការរបស់អ្នកប្រើប្រាស់ និងផ្តល់នូវផលិតផល ព័ត៌មាន និងសេវាកម្មដែលមានតុល្យភាពក្នុងតម្លៃសមរម្យ និងក្នុងទម្រង់ដែលអាចស្វែងរកបាន។

3.2 យើងខ្ញុំលើកកម្ពស់សុខុមាលភាព មិនត្រឹមតែដោយការធានាបាននូវសារធាតុចិញ្ចឹមសមស្របប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈរសជាតិឆ្ងាញ់ៗ ជម្រើសរបបអាហារចម្រុះ ការទទួលទានអាហាររួមគ្នា ដំណោះស្រាយចម្អិនអាហារឆ្លាតវៃ និងការពិចារណាលើបរិស្ថានពិភពលោក។

3.3 យើងខ្ញុំផ្តល់ជូននូវផលិតផលដែលមានអាហារូបត្ថម្ភ និងមានសុខភាពល្អ ព័ត៌មាន និងសេវាកម្មដែលឆ្លើយតបទៅនឹងតម្រូវការសុខភាពយ៉ាងទូលំទូលាយ - ចាប់ពីការបង្ការរហូតដល់ការព្យាបាល - ដែលជួយមនុស្សឱ្យរស់បានយូរ និងមានសុខភាពល្អ។

**គោលការណ៍និងសេចក្តីណែនាំជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីអាហារូបត្ថម្ភ
- សេចក្តីណែនាំអំពីយុទ្ធសាស្ត្រអាហារូបត្ថម្ភរបស់ Ajinomoto Group
- គោលការណ៍ជារួមក្នុងក្រុមស្តីពីការទទួលបាននូវផលិតផល

## 4. វិភាគទានចំពោះបរិស្ថាននិងនិរន្តរភាពនៃផែនដី

4.1 តាមរយៈការផ្តត់ផ្គង់ផលិតផល សេវាកម្ម និងសកម្មភាពអាជីវកម្មនានា យើងខ្ញុំធ្វើការជាមួយសហគមន៍ និងអតិថិជន ដើម្បីរួមរស់ជាមួយគ្នាដោយសុខដុមរមនាជាមួយផែនដី និងដើម្បីនាំមកនូវ “សង្គមមួយដែលផ្តោតលើការកែច្នៃឡើងវិញ” ប្រកបដោយចីរភាព ដែលធ្វើឱ្យការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការស្រូបយកមានតុល្យភាព ដើម្បីជួយកសាងពិភពលោកដែលមានការបំភាយឧស្ម័នសុទ្ធសូន្យ។ លើសពីនេះ យើងអនុវត្តគំនិតផ្តួចផ្តើមវិជ្ជមានចំពោះធម្មជាតិ ដើម្បីជៀសវាង ឬកាត់បន្ថយការបាត់បង់ និង/ឬស្តារ និងបង្កើតឡើងវិញនូវដើមទុនធម្មជាតិ និងជីវៈចម្រុះសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះដែលមិនអាចខ្វះបានសម្រាប់សកម្មភាពអាជីវកម្មរបស់យើងខ្ញុំ។

4.2 យើងខ្ញុំម្នាក់ៗក៏ត្រូវលើកកំពស់ការប្រើធនធានធម្មជាតិ ឬ ថាមពលឱ្យមានប្រសិទ្ធភាពខ្ពស់ និងការគិតដល់បរិស្ថាន។

**គោលការណ៍និងសេចក្តីណែនាំជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីបរិស្ថាន
- សេចក្តីណែនាំអំពីជីវចម្រុះនៃ Ajinomoto Group
- គោលការណ៍ជារួមក្នុងក្រុមស្តីពីសុខុមាលភាពសត្វ

# ការទទួលខុសត្រូវចំពោះអ្នកពាក់ព័ន្ធ

## 5. អតិថិជន : ការផ្តត់ផ្គង់ផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់និងសុវត្ថិភាពល្អ

5.1 យើងខ្ញុំត្រូវបើក្បច្ចេកទេសល្អៗ និងគំនិតច្នៃប្រឌិតសម្បូរបែប ដើម្បីអភិវឌ្ឍផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់និងសុវត្ថិភាព ដោយគិតអតិថិជនជាចម្បង ជានិច្ចជាកាល។

5.2 យើងខ្ញុំត្រូវផ្តល់នូវព័ត៌មានត្រឹមត្រូវ និងមានប្រយោជន៍ស្តីពីផលិតផលនិងសេវាកម្មរបស់យើងខ្ញុំ ដើម្បីទទួលនិងរក្សាជំនឿពីអតិថិជន ហើយសម្របទៅនឹងការរំពឹងទុករបស់អ្នកទាំងនោះ ហើយឱ្យគេស្របចិត្ត។

5.3 យើងខ្ញុំធានាថា ម៉ាយេធិញ និងការផ្សាយពាណិជ្ជកម្មរបស់យើងខ្ញុំ ត្រូវបានធ្វើឡើងដោយមានឥទ្ធិពលទៅវិញទៅមកនឹងអតិថិជនយើងខ្ញុំ ព្រមទាំងតាមវិធីដែលមានការទទួលខុសត្រូវ ជាពិសេសពេលមានការពាក់ព័ន្ធផ្ទាល់នឹងកុមារ។

**គោលការណ៍ជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីគុណភាព
- គោលការណ៍ជារួមក្នុងក្រុមស្តីពីសុវត្ថិភាពចំណីអាហារ
- គោលការណ៍ជារួមក្នុងក្រុមស្តីពីការប្រតិបត្តិទាក់ទងក្នុងម៉ាយេធិញ
- គោលការណ៍ជារួមក្នុងក្រុមស្តីពីការសរសេរលើកញ្ចប់

## 6. ដៃគូអាជីវកម្ម : ប្រតិបត្តិការប្រកបដោយតម្លាភាពនិងយុត្តិធម៌

6.1 ចំពោះប្រតិបត្តិការទាំងអស់របស់យើងខ្ញុំៗត្រូវខិតខំប្រឹងប្រែងរក្សាជានិច្ចនូវយុត្តិធម៌ និងតម្លាភាព និងទទួលស្គាល់ភាគីជាដៃគូដ៏សំខាន់នៃកិច្ចការជំនួញរបស់យើងខ្ញុំ។

6.2 យើងខ្ញុំត្រូវចាត់វិធានការឱ្យយល់ច្បាស់អំពីការគោរពច្បាប់ហាមឯកាធិបតេយ្យ និងច្បាប់ពាក់ព័ន្ធនឹងការប្រកួតប្រជែងនៃប្រទេសនីមួយៗដែលយើងខ្ញុំបង្កើតអាជីវកម្ម។ យើងមិនចូលរួមឃុបឃិតជាមួយនឹង គូប្រជែងរបស់យើងខ្ញុំ ដើម្បីកំណត់តម្លៃ ឬការលក់ / បរិមាណនៃការផលិត ដើម្បីកំណត់នូវការប្រកួតប្រជែង (ការតែល) ឬជជែកគ្នាអំពីការដាក់ថ្លៃឡើយ។ យើងខ្ញុំក៏មិនប្រើវិធីមិនស្មោះត្រង់ដើម្បីបំបាត់គូប្រជែងពីទីផ្សារ ឬរារាំងមិនឱ្យចូលទីផ្សារឡើយ។

6.3 ស្តីពីការជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញឱ្យយើងខ្ញុំ និងអ្នកដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យាការងារបន្ត យើងខ្ញុំធ្វើជាចក្ខុវិស័យសមស្របក្នុងការជ្រើសរើសអ្នកដែលជាដៃគូនោះ ដោយធ្វើការប្រៀបធៀបនិងវាយតម្លៃនូវតម្លៃ គុណភាព ល័ក្ខខ័ណ្ឌនៃសេវាកម្ម ដោយយុត្តិធម៌។ យើងខ្ញុំមិនប្រព្រឹត្តអំពើដែល ផ្តល់ផលប្រយោជន៍ទុច្ចរិតចំពោះភាគីដៃគូនៃប្រតិបត្តិការតាមរយៈការផ្តល់អាទិភាពក្នុងប្រតិបត្តិការទិញឡើយ។

6.4 យើងខ្ញុំចូលរួមជាមួយអ្នកម៉ាការបន្ត និងអ្នកផ្គត់ផ្គង់របស់យើងក្នុងកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីបំពេញទំនួលខុសត្រូវសង្គមរបស់យើង រួមទាំងការអភិរក្សបរិស្ថាន និងការការពារសិទ្ធិមនុស្ស ហើយយើងខ្ញុំធ្វើការជាមួយអ្នកផ្គត់ផ្គង់ ដើម្បីរួមចំណែកដល់ការទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ និរន្តរភាពនៃសហគមន៍តាមខ្សែសង្វាក់ផ្គត់ផ្គង់ទាំងមូល។

6.5 ស្តីពីទម្លាប់ក្នុងអាជីវកម្ម ឬការគួរសម ដូចជា ការជូនអំណោយ ឬបដិសណ្ឋារកិច្ច ឬបក្សជាដើម យើងខ្ញុំត្រូវប្រព្រឹត្តទៅតាមទម្លាប់ល្អ។

**គោលការណ៍និងសេចក្តីណែនាំជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីលទ្ធកម្ម
- សេចក្តីណែនាំអំពីការផ្គត់ផ្គង់ក្រដាសនៃ Ajinomoto Group
- សេចក្តីណែនាំអំពីការផ្គត់ផ្គង់ប្រេងដូងនៃ Ajinomoto Group
- សេចក្តីណែនាំអំពីការផ្គត់ផ្គង់កាហ្វេនៃ Ajinomoto Group
- សេចក្តីណែនាំអំពីការផ្គត់ផ្គង់សណ្តែកសៀងនៃ Ajinomoto Group
- សេចក្តីណែនាំអំពីការផ្គត់ផ្គង់អំពៅនៃ Ajinomoto Group
- សេចក្តីណែនាំអំពីសាច់គោនៃ Ajinomoto Group
- គោលការណ៍ជារួមក្នុងក្រុមសម្រាប់អ្នកផ្គត់ផ្គង់
- សេចក្តីណែនាំអំពីគោលការណ៍ជារួមក្នុងក្រុមសម្រាប់អ្នកផ្គត់ផ្គង់

## 7. វិនិយោគិន និងម្ចាស់ភាគហ៊ុន : ទំនុកចិត្ត និងការទទួលខុសត្រូវ

7.1 យើងខ្ញុំត្រូវចំណាយកិច្ចគ្រប់គ្រងឱ្យបានល្អ បង្កើតផលចំណេញជូនម្ចាស់ភាគហ៊ុនឱ្យបានសមរម្យនិងសមស្រប ដើម្បីសម្រេចបាននូវកំណើនតម្លៃក្រុមហ៊ុនជាប្រចាំ។

7.2 យើងខ្ញុំត្រូវបង្ហាញព័ត៌មានឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ជូនចំពោះម្ចាស់ភាគហ៊ុន និងវិនិយោគិន ជាដើម ដើម្បីឆ្លើយតបឱ្យមានសមភាព និងស្មោះត្រង់ ទៅតាមការរំពឹងទុក និងទំនុកចិត្តរបស់ពួកគេ។

7.3 យើងបង្កើតទំនាក់ទំនងដែលមានជំនឿទុកចិត្ត និងលើកកម្ពស់កិច្ចសហប្រតិបត្តិការដោយចូលរួមក្នុងកិច្ចសន្ទនាទ្វេភាគីដែលកំពុងបន្តជាមួយអ្នកពាក់ព័ន្ធសម្បូរបែបរបស់យើង។

7.4 យើងខ្ញុំត្រូវរក្សា និងដំណើរការក្របខ័ណ្ឌគ្រប់គ្រងផ្ទៃក្នុងសមស្រប ដើម្បីធានានូវជំនឿ និងភាពត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុដែលយើងខ្ញុំបានផ្តល់ជូនចំពោះម្ចាស់ភាគហ៊ុននិងវិនិយោគិន។

7.5 យើងខ្ញុំមិនបំពានច្បាប់ស្តីពីប្រតិបត្តិការដែលមានរវាងក្នុង ដូចជាការជួញដូរភាគហ៊ុន ជាដើម ដោយប្រើព័ត៌មានដែលមិនបានបង្ហាញជាសាធារណៈ របស់ក្រុមហ៊ុននៃ Ajinomoto Group ឬ/និងរបស់ដៃគូអាជីវកម្មឡើយ។

7.6 យើងបំពេញទំនួលខុសត្រូវសង្គមរបស់យើង ដោយការអនុលោមតាមច្បាប់ពន្ធដារ និងបង់ពន្ធសមស្របនៅក្នុងប្រទេសនីមួយៗដែលយើងប្រតិបត្តិការ ព្រមទាំងគ្រប់គ្រងហានិភ័យពន្ធឱ្យបានសមស្រប។

**គោលការណ៍និងសេចក្តីណែនាំជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីពន្ធដារសកល
- គោលការណ៍ជារួមក្នុងក្រុមស្តីពីការចែករំលែកព័ត៌មានជាមួយម្ចាស់ភាគហ៊ុននិងវិនិយោគិន
- សេចក្តីណែនាំអំពីការបង្ការការជួញដូរភាគហ៊ុនដោយផ្អែកលើព័ត៌មានផ្ទៃក្នុង

## 8. សហគមន៍ : ធ្វើការងារជាមួយសហគមន៍

8.1 យើងខ្ញុំខិតខំប្រឹងប្រែងធ្វើវិភាគទានជាវិជ្ជមានចំពោះសង្គម ក្នុងការបង្កើតសហគមន៍ដែលយើងបង្កើតអាជីវកម្ម ឱ្យមានសុខភាពល្អ និងឆ្ពោះទៅរកសង្គមផ្សេងទៀត។ យើងចាប់អារម្មណ៍ទៅលើការអភិវឌ្ឍវប្បធម៌ និងអប់រំនៃសហគមន៍នីមួយៗដែលយើងធ្វើអាជីវកម្ម។

8.2 ប្រសិនបើក្រុមហ៊ុនធ្វើការបរិច្ចាគដល់អង្គការណាមួយ យើងខ្ញុំត្រូវកំណត់យ៉ាងច្បាស់នូវគោលបំណង និងសារៈសំខាន់ក្នុងសង្គម ធ្វើការសម្រេចចិត្តទាំងអស់ស្របតាមច្បាប់ផ្ទៃក្នុង អនុវត្តតាមនីតិវិធីចាំបាច់ទាំងអស់ និងធានាការអនុលោមតាមច្បាប់ជាធរមាន និងតម្លាភាព។

8.3 យើងខ្ញុំម្នាក់ៗត្រូវខំប្រឹងប្រែងចូលរួមធ្វើសកម្មភាពដែលជាវិភាគទានដល់សង្គម ក្នុងនាមជាសមាជិកនៃសង្គមក្នុងតំបន់។

8.4 យើងខ្ញុំយល់ដឹងថា រាល់ពេលដែលអ្នកណាម្នាក់ ឬបុគ្គលិកណាម្នាក់នៃក្រុមយើង ធ្វើការប្រតិបត្តិទាក់ទងនឹងសាធារណជន គឺអ្នកនោះធ្វើសកម្មភាពក្នុងនាមជាតំណាងក្រុមហ៊ុន ហើយសកម្មភាពទាំងនោះត្រូវបានគ្រប់គ្រងដោយឥរិយាបថសង្គមជារៀងរាល់ពេល។

**គោលការណ៍ជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីការពង្រឹងសហគមន៍

## 9. អ្នកនយោបាយ និងរដ្ឋាភិបាល : ទំនាក់ទំនងប្រកបដោយតម្លាភាព

9.1 ពេលចូលរួមក្នុងសកម្មភាពនយោបាយ យើងខ្ញុំត្រូវធ្វើសកម្មភាពទាំងនោះក្នុងនាមជាបុគ្គល ហើយយើងខ្ញុំត្រូវធ្វើតែក្រៅពេលធ្វើការ និងក្រៅកន្លែងធ្វើការ ដើម្បីជៀសវាងការយល់ច្រឡំណាមួយថា សកម្មភាពបែបនេះតំណាងឱ្យក្រុមហ៊ុន។

9.2 យើងខ្ញុំមិនជូនអំណោយ ការកម្សាន្ត ប្រាក់ ឬអត្ថប្រយោជន៍ផ្សេងទៀតដែលបង្កើតជាសំណូកដល់មន្ត្រីសាធារណៈក្នុងស្រុក ឬក្រៅស្រុក ឬបុគ្គលដែលមានឋានៈស្មើនឹងពួកគេ ដោយមិនគិតពីមធ្យោបាយណាមួយឡើយ។ យើងរក្សាទំនាក់ទំនងល្អ និងធម្មតាជាមួយរដ្ឋាភិបាល និងមន្ត្រីសាធារណៈ។

9.3 ប្រសិនបើក្រុមហ៊ុនចូលរួមក្នុងសកម្មភាពនយោបាយ ឬធ្វើអន្តរកម្មជាមួយស្ថាប័នរដ្ឋបាល ឬសាធារណៈតាមរយៈការ lobbying ឬសកម្មភាពផ្សេងទៀត យើងខ្ញុំកំណត់យ៉ាងច្បាស់អំពីគោលបំណង ភាពចាំបាច់ ភាពសមស្រប និងសារៈសំខាន់ក្នុងសង្គម ចាត់វិធានការទាំងអស់ស្របតាមវិធានផ្ទៃក្នុង ដើម្បីសម្រេចថា តើត្រូវបន្តឬអត់ អនុវត្តតាមនីតិវិធីចាំបាច់ទាំងអស់ និងធានាការអនុលោមតាមច្បាប់ជាធរមាន និងតម្លាភាព។

**គោលការណ៍ជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីការបង្ការអំពើពុករលួយ
- គោលការណ៍ជារួមក្នុងក្រុមស្តីពីសកម្មភាពនយោបាយ និងការចូលរួមចំណែកនយោបាយ
- គោលការណ៍ជារួមក្នុងក្រុមស្តីពីសកម្មភាព lobbying

## 10. បុគ្គលិក : ការបណ្តុះបណ្តាលបុគ្គលិក និងការធានាសុវត្ថិភាព

10.1 យើងខ្ញុំផ្តល់ឱកាសការងារស្មើភាពគ្នានៅក្នុងបរិយាកាសកន្លែងធ្វើការដែលគោរពសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប និងដែលអនុញ្ញាតឱ្យបុគ្គលិករបស់យើងខ្ញុំអភិវឌ្ឍ និងប្រើប្រាស់ជំនាញ សមត្ថភាព បទពិសោធន៍របស់ពួកគេបានយ៉ាងពេញលេញ និងបង្កើនការលើកទឹកចិត្តរបស់ពួកគេតាមរបៀបដែលគោរពភាពចម្រុះ ចរិតលក្ខណៈ និងបុគ្គលភាពរបស់ពួកគេ។

10.2 យើងខ្ញុំត្រូវមានចក្ខុវិស័យជាសកល លើការធ្វើការជាក្រុម បង្ហាញគំនិតច្នៃប្រឌិត និងឧត្តមគតិជាអ្នកដឹកនាំផ្លូវ និងធ្វើវិភាគទានដើម្បីអភិវឌ្ឍ Ajinomoto Group របស់យើងខ្ញុំទាំងមូល។

10.3 យើងខ្ញុំត្រូវខិតខំប្រឹងប្រែងធ្វើវិភាគទានដើម្បីឱ្យជីវភាពរស់នៅរបស់បុគ្គលិកកាន់តែប្រសើរ ហើយធ្វើឱ្យសង្គមរុងរឿង តាមរយៈការអភិវឌ្ឍឱ្យសហគមន៍ប្រកបដោយនិរន្តរភាព។ ជាទីបញ្ចប់ យើងខ្ញុំត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍខ្លួនឯងជាប្រចាំ តាមរយៈគំនិត និងកម្មវិធីថ្មីៗ។

10.4 យើងចង់ឱ្យបរិយាកាសការងារល្អ ដើម្បីលើកកម្ពស់ភាពសប្បាយចិត្តក្នុងការងារ និងបង្កើនផលិតភាព។

10.5 យើងខិតខំប្រឹងប្រែងរៀបចំបរិយាកាសការងារឱ្យមានផាសុខភាព និងទំនាក់ទំនងល្អ ដោយគ្មានការរើសអើង គ្មានការរំលោភបំពាន ហើយមានការគោរពគ្នាទៅវិញទៅមក។

10.6 យើងខ្ញុំជឿជាក់ថា មូលដ្ឋានគ្រឹះសម្រាប់ការរីកចម្រើនជាបន្តបន្ទាប់របស់ Ajinomoto Group ស្ថិតនៅលើសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់បុគ្គលិករបស់យើងខ្ញុំ។ យើងខ្ញុំធ្វើការជាមួយមន្ត្រី និងបុគ្គលិករបស់យើងខ្ញុំ ដើម្បីរក្សា និងកែលម្អសុខភាពក្រុមការងាររបស់យើងខ្ញុំ។

10.7 យើងខ្ញុំធ្វើសកម្មភាពដោយផ្អែកលើគោលការណ៍ដែលថា "យើងត្រូវតែផ្តល់អាទិភាពទៅលើការការពារជីវិតដោយសុវត្ថិភាព" ហើយបន្តកែលម្អសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការតាមរយៈការចូលរួមពីមន្ត្រី និងបុគ្គលិកទាំងអស់ ដើម្បីធានាសុវត្ថិភាពរបស់បុគ្គលិកទាំងអស់ដែលធ្វើការឱ្យ Group ។

**គោលការណ៍ជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីធនធានមនុស្ស
- គោលការណ៍ជារួមក្នុងក្រុមស្តីពីសុវត្ថិភាពនិងសុខភាពការងារ

# និរន្តរភាពផ្ទៃក្នុង និងស្តង់ដារនៃការប្រព្រឹត្តផ្ទាល់ខ្លួន

## 11. ការការពារ និងគ្រប់គ្រងទ្រព្យសម្បត្តិ និងព័ត៌មានរបស់ក្រុមហ៊ុន

11.1 យើងខ្ញុំត្រូវការពារ និងគ្រប់គ្រងទ្រព្យសម្បត្តិទាំងរូបីយ៍ ទាំងអរូបីយ៍ រួមទាំងការសម្ងាត់ និងកម្មសិទ្ធិបញ្ញារបស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ រួមទាំងទិន្នន័យរបស់ក្រុមហ៊ុន ការសម្ងាត់នៃពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញា (រួមទាំងម៉ាកយីហោ)។

11.2 យើងខ្ញុំយល់អំពីសារៈសំខាន់នៃការការពារឯកជនភាពនិងព័ត៌មានបុគ្គលឯកជន ហើយទទួលយកប្រើប្រាស់ និងផ្តល់ព័ត៌មានរបស់បុគ្គលឯកជនតែតាមវិធីសមស្រប។ យើងខ្ញុំគ្រប់គ្រងព័ត៌មានបុគ្គលឯកជនទាំងអស់យ៉ាងតឹងរ៉ឹង ដើម្បីការពារការលេចធ្លាយទៅកាន់ភាគីខាងក្រៅ ការបាត់បង់ ឬការខូចខាត ហើយយើងខ្ញុំគោរពភាពឯកជនភាពរបស់អ្នកពាក់ព័ន្ធទាំងអស់។

11.3 យើងខ្ញុំទាញយកអត្ថប្រយោជន៍ពីកម្មសិទ្ធិបញ្ញារបស់យើង ដើម្បីបង្កើតផលិតផល និងសេវាកម្មដែលមានតម្លៃបន្ថែមខ្ពស់ បង្កើនតម្លៃបន្ថែមទៀត និងចូលរួមចំណែកដល់ការអភិវឌ្ឍសង្គម។

11.4 យើងខ្ញុំត្រូវគោរពកម្មសិទ្ធិបញ្ញាដែលតតិយជនកាន់កាប់។

11.5 យើងខ្ញុំចាត់ទុកសន្តិសុខព័ត៌មានជាអាទិភាពនៅក្នុងសកម្មភាពសាជីវកម្មរបស់យើង ហើយខិតខំការពារព័ត៌មានពីការគំរាមកំហែងទាំងអស់ រួមទាំងការវាយប្រហារពីខាងក្រៅផងដែរ។

**គោលការណ៍ជារួមក្នុងក្រុម**

- គោលការណ៍ជារួមក្នុងក្រុមស្តីពីសុវត្ថិភាពព័ត៌មាន
- គោលការណ៍ជារួមក្នុងក្រុមស្តីពីឯកជនភាព
- គោលការណ៍ជារួមក្នុងក្រុមស្តីពីកម្មសិទ្ធិបញ្ញា

## 12. ការបំបាត់ភាពចម្លែករវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍អាជីវកម្ម

12.1 យើងខ្ញុំត្រូវខិតខំប្រឹងប្រែងធ្វើឱ្យគ្មានទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន រួមទាំងស្ថានភាពដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ Ajinomoto Group។

12.2 យើងខ្ញុំមិនយក ឬបង្ហាញទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ក្រុមហ៊ុនទៅខាងក្រៅក្រុមហ៊ុនដោយគ្មានការអនុញ្ញាតឡើយ។ យើងខ្ញុំប្រើប្រាស់វាសម្រាប់តែគោលបំណងអាជីវកម្មប៉ុណ្ណោះ មិនមែនសម្រាប់ការស្វែងរកផលប្រយោជន៍ឯកជនទេ។

12.3 យើងខ្ញុំមិនអនុញ្ញាតឱ្យមានផលប្រយោជន៍ផ្ទាល់ខ្លួនណាមួយតាមរយៈការងាររបស់ក្រុមហ៊ុនទេ ដូចជាការប្រើប្រាស់មូលនិធិរបស់ក្រុមហ៊ុនសម្រាប់គោលបំណងឯកជន ឬទង្វើណាមួយដែលអាចបង្កើនការសង្ស័យបែបនេះ ដោយមិនគិតពីចំនួនទឹកប្រាក់នោះទេ។

12.4 យើងខ្ញុំយល់ច្បាស់ថា ទំនាក់ទំនងអាជីវកម្មដែលត្រូវបានបង្កើតឡើងដោយបុគ្គលិក គឺជាទ្រព្យសម្បត្តិនៃក្រុមហ៊ុន ទោះបីជាបុគ្គលិកនោះចូលនិវត្តក៏ដោយ។

12.5 ពេលបង្ហោះព័ត៌មានតាមរយៈបណ្តាញសង្គម យើងខ្ញុំត្រូវបង្ហាញឱ្យច្បាស់ថា វាជាព័ត៌មានផ្លូវការរបស់ក្រុមហ៊ុន ឬជាការបង្ហោះផ្ទាល់ខ្លួន។ ទោះបីជាជាការបង្ហោះផ្ទាល់ខ្លួនក៏ដោយ យើងខ្ញុំត្រូវទទួលខុសត្រូវក្នុងនាមជាសមាជិកនៃ Ajinomoto Group ហើយមិនធ្វើអ្វីដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ឬអោយខូចទ្រព្យសម្បត្តិផ្សេងទៀតរបស់ក្រុមហ៊ុនឡើយ។

## Hotline (ទូរស័ព្ទទាន់ហេតុការណ៍)

- Ajinomoto Group បានបង្កើតវិធីសាស្រ្តសម្រាប់បុគ្គលិកធ្វើរបាយការណ៍ស្តីពីសកម្មភាពបំពានច្បាប់ និងបញ្ហាពាក់ព័ន្ធនឹង “គោលការណ៍ជារួមនៃក្រុម” តាមរយៈការផ្តល់របាយការណ៍អនាមិកដែលមានពន្យល់ក្នុងជំពូកទី 1។
- ព័ត៌មានផ្ទាល់ខ្លួននឹងត្រូវបានការពារ ហើយឯកជនភាពនឹងត្រូវបានគោរព។ គ្មានអ្នកផ្តល់ព័ត៌មានណាមួយនឹងត្រូវបានចាត់ចែងដោយអវិជ្ជមាន ដោយសារតែបានធ្វើរបាយការណ៍នោះទេ។
- បន្ថែមលើបណ្តាញហាត់ឡាញទៅក្រុមហ៊ុននីមួយៗ, របាយការណ៍នានាក៏អាចធ្វើបានតាមបណ្តាញខាងក្រោមនេះដែរ ៖

**Ajinomoto Group Hotline**

WEB: https://ml.helpline.jp/g-hotline/

ID: hotline PW: ajinomoto

* អាចចូលប្រើបាន 24 ម៉ោងក្នុងមួយថ្ងៃ, 365 ថ្ងៃក្នុងមួយឆ្នាំ, ជា 22 ភាសា

* ប្រសិនជារបាយការណ៍ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងនាយក ឬមន្ត្រី សូមជ្រើសរើស Hotline ទៅកាន់គណៈកម្មាធិការសវនកម្ម។

**Ajinomoto Co., Inc.**

15-1, Kyobashi 1-chome, Chuo-ku,
Tokyo 104-8315 Japan
Tel: +81 (3) 5250-8111
URL: http://www.ajinomoto.com/en/

Eat Well, Live Well.

AJINOMOTO

ធ្វើនៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០១៨
កំណែទី ២ ថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២១
កំណែទី ៣ ថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២៣
កំណែទី ៤ ថ្ងៃទី ១ ខែមេសា ឆ្នាំ ២០២៦